# សំណុំរឿង ០០២/០១

## បណ្តឹងសាទុក្ខ

សំណុំរឿង ០០២/០១ គឺជាការជំនុំជម្រះក្តីវគ្គទី ១ នៅក្នុងសំណុំរឿង ០០២ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ដែលគេស្គាល់ជាទូទៅថាជាសាលាក្តីខ្មែរក្រហម។ ខៀវ សំផន និង នួន ជា គឺជាជនជាប់ចោទនៅក្នុងរឿងក្តីនេះ។ សំណុំរឿង ០០២/០១ បានចាប់ផ្តើមជំនុំជម្រះក្តីនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ហើយសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបានប្រកាសនៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤។ ទាំងសហព្រះរាជអាជ្ញា ទាំងមេធាវីការពារក្តី បានប្តឹងសាទុក្ខជំទាស់នឹងសាលក្រមនេះ។ លទ្ធផលនៃបណ្តឹងសាទុក្ខទាំងនេះនឹងត្រូវអង្គជំនុំជម្រះតុលាការកំពូលប្រកាសនៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦។

សវនាការមានចំនួន
**២២២** ថ្ងៃ
នៅក្នុងសំណុំរឿង ០០២/០១




សក្ខីកម្មចំនួន **៩២**

ត្រូវបានស្តាប់ដោយ
អង្គជំនុំជម្រះ
សាលាដំបូងក្នុងនោះ

-សាក្សីចំនួន ៥៨ នាក់
-ដើមបណ្តឹងរដ្ឋប្បវេណី ៣១
-អ្នកជំនាញចំនួន ៣ រូប






សាធារណជនចំនួន
**១០៤ ៤៤៤** នាក់
បានចូលរួមសវនាការដោយផ្ទាល់




សាធារណជនទូទៅ ទាំងជាតិ និងអន្តរជាតិចូលរួមសវនាការ។ ក្រៅពីនេះ មានមន្ត្រីរដ្ឋាភិបាល អ្នកការទូត អ្នកសារព័ត៌មានតំណាងអង្គការក្រៅរដ្ឋាភិបាល និងដើមបណ្តឹងរដ្ឋប្បវេណី

## តើមានបទចោទអ្វីខ្លះ?

បទចោទប្រឆាំងនឹង នួន ជា និង ខៀវ សំផន ស្ថិតនៅក្នុងប្រភេទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ៖

-ការធ្វើមនុស្សឃាត
-ការសម្លាប់រង្គាល
-ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ
-អំពើអមនុស្សធម៌ផ្សេងៗទៀតក្នុងរូបភាពជាការផ្លាស់ទីលំនៅដោយបង្ខំ ការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និងការបាត់ខ្លួនដោយបង្ខំ

សាលក្រមឆ្នាំ ២០១៤ របស់អង្គជំនុំជម្រះសាលាដំបូងមិនទាន់ចូលជាស្ថាពរនៅឡើយទេ រហូតដល់មានការប្រកាសសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខ។



### ខៀវ សំផន

កើតនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៣១ នៅស្វាយរៀង

គាត់បានសិក្សានៅប្រទេសបារាំង និងបានបោះពុម្ពផ្សាយនិក្ខេបបទថ្នាក់បណ្ឌិតរបស់គាត់ស្តីពី "ការអភិវឌ្ឍសេដ្ឋកិច្ច និងឧស្សាហកម្មនៅកម្ពុជា"។

គាត់បានក្លាយជាប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ។

គាត់បានធ្វើជាតំណាងកម្ពុជានៅក្នុងសន្និសីទអន្តរជាតិស្តីពីកម្ពុជានៅទីក្រុងប៉ារីស។

គាត់ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧។



### នួន ជា

កើតនៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩២៦ នៅបាត់ដំបង

គាត់បានសិក្សាច្បាប់នៅសាកលវិទ្យាល័យ Thammasat នៅទីក្រុងបាងកក ប្រទេសថៃ។

គាត់បានក្លាយជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជានៅសម័យកម្ពុជាប្រជាធិបតេយ្យ។

គាត់នៅជាមួយខ្មែរក្រហម ហើយមានកិច្ចព្រមព្រៀងមួយជាមួយរដ្ឋាភិបាលកម្ពុជា ដែលអនុញ្ញាតឱ្យគាត់រស់នៅជាប់ព្រំដែនថៃ។

គាត់ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៩ ខែ កញ្ញា ឆ្នាំ ២០០៧។

## សាលក្រមបានសម្រេចអ្វីខ្លះ?

នៅខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានរកឃើញថា នួន ជា និង ខៀវ សំផន**មានពិរុទ្ធពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ**។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា៖

-យ៉ាងហោចណាស់មនុស្សចំនួន ២ លាននាក់ ត្រូវបានបង្ខំឱ្យផ្លាស់ទីលំនៅចេញពីភ្នំពេញ កាលពីខែ មេសា ឆ្នាំ ១៩៧៥ ក្នុងស្ថានភាពគួរឱ្យភ័យខ្លាច និងហិង្សា។

-យ៉ាងហោចណាស់មនុស្សចំនួន ៣០០ នាក់ទៅ ៤០០ ០០០ នាក់ ត្រូវបានផ្លាស់ទីលំនៅដោយបង្ខំក្នុងស្ថានភាពលំបាកស្រដៀងគ្នានេះ ចាប់ពីខែ កញ្ញា ឆ្នាំ ១៩៧៥ ដល់ដើមឆ្នាំ ១៩៧៧។

-យ៉ាងហោចណាស់ទាហាន លន់ នល់ ចំនួន ២៥០ នាក់ ត្រូវបានស្លាប់ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។

# សំណុំរឿង ០០២/០១

## បណ្តឹងសាទុក្ខ

បន្ទាប់ពីការប្រកាសសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០១ មក មេធាវីការពារក្តី និងសហព្រះរាជអាជ្ញា បានដាក់បណ្តឹងសាទុក្ខភ្លាមជូនទៅអង្គជំនុំជម្រះសាលាដំបូង។ បន្ទាប់មក  បណ្តឹងសាទុក្ខទាំងនោះត្រូវបានបញ្ជូនទៅអង្គជំនុំជម្រះតុលាការកំពូល។ បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី គឺផ្តែកទៅលើការចោទប្រកាន់អំពីកំហុសអង្គច្បាប់ និងកំហុសអង្គហេតុ មានន័យថា មេធាវីការពារក្តី ប្តឹងតវ៉ាថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការអនុវត្តច្បាប់ និងអង្គហេតុដែលអង្គជំនុំជម្រះសាលាដំបូង យកជាមូលដ្ឋាននៅក្នុងសាលក្រមរបស់ខ្លួន។ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាមិនបានស្នើសុំឲ្យកែប្រែសាលក្រមឡើយ ប៉ុន្តែ ស្នើសុំឲ្យប្រកាសថា ទម្រង់ទី ៣ នៃការទទួលខុសត្រូវចំពោះសហឧក្រិដ្ឋកម្មរួម អាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក។

## តើបណ្តឹងសាទុក្ខមានដំណើរការនីតិវិធីយ៉ាងណា?

១ 

សាលក្រមត្រូវបានប្រកាសដោយអង្គជំនុះជម្រះសាលាដំបូង។ បន្ទាប់មក មេធាវីការពារក្តី និងសហព្រះរាជអាជ្ញា អាចដាក់បណ្តឹងសាទុក្ខ។ មេធាវីការពារក្តី និងសហព្រះរាជអាជ្ញាបានដាក់បណ្តឹងសាទុក្ខរួចហើយ។ មេធាវីការពារក្តីនិងសហព្រះរាជអាជ្ញា ត្រូវដាក់បណ្តឹងសាទុក្ខជូនទៅអង្គជំនុះជម្រះសាលាដំបូង បន្ទាប់មកបណ្តឹងសាទុក្ខទាំងនោះត្រូវបញ្ជូនទៅអង្គជំនុំជម្រះតុលាការកំពូល (អ័.ជ.ត័.ក)។

២ 

អ.ជ.ត.ក ពិចារណាអំពីភស្តុតាងនិងសេចក្តីសន្និដ្ឋាននានា ហើយធ្វើការពិភាក្សាសម្រេច។ អ.ជ.ត.ក ត្រូវតែសម្រេចថា តើមានកំហុសអង្គច្បាប់ ឬអង្គហេតុដែលប៉ះពាល់ដល់សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែរឬទេ។

៣ 

អ.ជ.ត.ក អាចប្រកាសសាលដីកាបាន លុះត្រាតែមានសំឡេងគាំទ្រពីចៅក្រមចំនួន ៥ រូបក្នុងចំណោមចៅក្រមសរុបចំនួន ៧ រូប គឺចៅក្រមជាតិ ៤ រូប និងចៅក្រមអន្តរជាតិ ៣ រូប។ អ.ជ.ត.ក នឹងប្រកាសសាលដីកាលើបណ្តឹងសាទុក្ខ សំណុំរឿង ០០២/០១ នៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៦។

## សេចក្តីសង្ខេបនៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី

នួន ជា ស្នើសុំឲ្យច្រានចោលសាលក្រម ហើយឲ្យគាត់រួចផុតពីបទចោទទាំងអស់។

ខៀវ សំផន ស្នើសុំឲ្យច្រានចោលសាលក្រម ហើយឲ្យគាត់រួចផុតពីបទចោទទាំងអស់។ បើមិនដូច្នេះទេ គាត់ស្នើសុំឲ្យបន្ថយការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតរបស់គាត់មកនៅត្រឹមរយៈពេលកំណត់មួយ។

តើបណ្តឹងសាទុក្ខមានមូលដ្ឋានជំទាស់ចំនួនប៉ុន្មាន?

នួន ជា មានមូលដ្ឋានជំទាស់ចំនួន ២២៣ នៅក្នុងបណ្តឹងសាទុក្ខរបស់គាត់។

ខៀវ សំផន មានមូលដ្ឋានជំទាស់ចំនួន ១៤៨ នៅក្នុងបណ្តឹងសាទុក្ខរបស់គាត់។

តើបណ្តឹងសាទុក្ខមានអ្វីខ្លះ?

-ទឡ្ហីករណ៍ទាក់ទងនឹងធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក និងភាពយុត្តិធម៌នៃដំណើរការនីតិវិធី។

-ទឡ្ហីករណ៍ទាក់ទងនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះភស្តុតាង។

-ទឡ្ហីករណ៍ទាក់ទងនឹងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានផ្តន្ទាទោស។

-ទឡ្ហីករណ៍ទាក់ទងនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទ។

-ខៀវ សំផន លើកឡើងពីទឡ្ហីករណ៍ទាក់ទងនឹងការសម្រេចទោសចំពោះគាត់។

## សេចក្តីសង្ខេប នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា

សហព្រះរាជអាជ្ញា ស្នើសុំឲ្យ អ.ជ.ត.ក ប្រកាសថាទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម (ទម្រង់ទី ៣) អាចអនុវត្តបាននៅចំពោះមុខអ.វ.ត.ក។

សហព្រះរាជអាជ្ញា ស្នើសុំឲ្យ អ.ជ.ត.ក សម្រេចថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសម្រេចថា ទម្រង់ទូលាយនៃការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម (ទម្រង់ទី ៣) មិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥ ទេ។

ឧទាហរណ៍?

-ជនជាប់ចោទបញ្ជាឲ្យ យោធាវ័យក្មេងយកនារីៗចេញពីផ្ទះដើម្បីធ្វើទារុណកម្ម ឬសម្លាប់។ ក្នុងអំឡុងពេលនោះ មានស្ត្រី និងក្មេងស្រីត្រូវគេរំលោភផ្លូវភេទ។ ប្រសិនបើមានភស្តុតាងបញ្ជាក់ថាជនជាប់ចោទបានដឹងថាការរំលោភផ្លូវភេទអាចកើតឡើងដោយសារតែផែនការឧក្រិដ្ឋរបស់ខ្លួន តែយល់ឃើញថាមិនអី ហើយនៅតែបន្តបញ្ជាឲ្យធ្វើដូច្នេះទៀត ដូច្នេះគាត់អាចត្រូវដាក់ឲ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋរំលោភផ្លូវភេទ។